**ACIAR Project ASEM/2006/130 “Production and marketing of maize And soybean in northwestern Cambodia”**

# វិធានការចំរុះគ្រប់គ្រងកត្តាចង្រៃ សម្រាប់ដំណាំសណ្តែកសៀង នៅកម្ពុជា







**ប៊ប ម៉ាទីន ស្តេពហ្វេនី បែលហ្វៀល & ឌួច វ៉ាន់**

Primary Industries Innovation Centre, University of New England, Armidale NSW 2351, Australia, Phone: +61 2 6773 2869, Fax: +61 2 6773 3238
E-mail: bob.martin@une.edu.au

EUROPEAN UNION
Australian Government
AusAID
Australian Government
Australian Centre for International Agricultural Research
CCPMP Cambodia Crop Production & Marketing Project
care

# ផ្នែកទី ១

## សេចក្តីផ្តើមចំពោះ សិក្ខាសាលា និង អាយ ភី អឹម (IPM)

### សេចក្តីផ្តើមចំពោះសិក្ខាសាលា?

**សកម្មភាព ១. កំណត់ដំណាក់កាលលូតលាស់របស់សណ្តែកសៀង**

**គោលបំណង:** នៅចុងបញ្ចប់នៃសិក្ខាសាលា អ្នកចូលរួមនឹងអាចកំណត់ពីដំណាក់កាលលូតលាស់របស់ដើមសណ្តែកសៀង ។

**តំរូវការសំភារ:**

១. អ្នកចូលរួម គួរតែយកដើមសណ្តែកសៀង ៥ដើម ពីចំការផ្សេងៗ មុនពេលសិក្ខាសាលា ។

២. ឯកសារសិក្ខាសាលាជំពូកទី២ ទំព័រ៦-១៥

**សកម្មភាព ២. កំណត់សត្វល្អិត**

**គោលបំណង:** នៅចុងបញ្ចប់នៃសិក្ខាសាលា អ្នកចូលរួម នឹង អាចវែកញែករវាងសត្វមានប្រយោជន៍ និងសត្វចង្រៃ ។

**តំរូវការសំភារ:**

១. អ្នកចូលរួម គួរចាប់សត្វល្អិតច្រើនប្រភេទ ពីចំការរបស់ពួកគេ មុនពេលសិក្ខាសាលា

២. ដបថ្លាស្វិចមានគំរបដោយទម្លុះប្រហោង

**សកម្មភាព ៣. ត្រួតពិនិត្យចំនួនសត្វក្នុងចំការ**

**គោលបំណង:** នៅចុងបញ្ចប់នៃសិក្ខាសាលា អ្នកចូលរួមនឹងអាចបង្ហាញកសិករផ្សេងៗទៀត ពីរបៀបធ្វើសំណាកនៅចំការ ។

**តំរូវការសំភារ:**

១. សំណាញ់បក់ និង ផ្ទាំងក្រណាត់សំរាប់គោះ

២. សៀវភៅសរសេរ និងតារាងកត់ត្រា

**សកម្មភាព ៤.ការគណនាកំរិតមាត់ទ្វារសេដ្ឋកិច្ច និងពិភាក្សាអំពី ជំរើស អាយ ភី អឹម**

**គោលបំណង:** នៅចុងបញ្ចប់នៃ សិក្ខាសាលានេះអ្នកចូលរួម នឹងអាច គណនាចំនុចកំណត់ត្រូវបាញ់ថ្នាំសំរាប់កត្តាចង្រៃនៅក្នុងសណ្តែកសៀង ។

**តំរូវការសំភារ:**

១. ឯកសារសិក្ខាសាលា ជំពូក ៧ - ៨ ។

២. សៀវភៅសរសេរ ម៉ាស៊ីនគិតលេខ និងតារាងកត់ត្រា ។

## ផ្តើមចំពោះ ឧបាយការចំរុះគ្រប់គ្រងកត្តាចង្រៃ (អា ភី អឹម - IPM)?

អាយ ភី អឹម (IPM) ពាក់ពន្ធ័ទៅនឹងការអនុវត្តន៍ ដោយរួមបញ្ចូលវិធីសាស្រ្តគ្រប់គ្រងច្រើនយ៉ាង ដើម្បីកាត់បន្ថយការបំផ្លាញពីកត្តាចង្រៃដោយការពារសត្វល្អិត មានប្រយោជន៍ហើយកាត់បន្ថយការប្រើប្រាស់ថ្នាំកំចាត់សត្វល្អិត ។



គោលបំណងរបស់ អាយ ភី អឹម (IPM) គឺដើម្បីរក្សាកត្តាចង្រៃនៅចំនួនតិច ដើម្បី កុំឱ្យពួកវាបំផ្លាញធ្ងន់ធ្ងរ ។ នេះធ្វើឡើងដោយការត្រួតពិនិត្យជាប្រចាំ ហើយពិចារណាយ៉ាងប្រុងប្រយ័ត្នចំពោះដំណាំ ព្រមទាំងទៅលើសកម្មភាពសត្វល្អិតមុនពេលការសំរេចចិត្តធ្វើថ្នាំកំចាត់សត្វល្អិត ។

# ផ្នែកទី២

## វគ្គលូតលាស់របស់ដំណាំសណ្តែកសៀង

វគ្គនៃវដ្តជីវិតរបស់សណ្តែកសៀង ត្រូវបានបែងចែកជាពីរ គឺ វគ្គលូតលាស់ និងវគ្គបន្តពូជ (មើលតារាងខាងក្រោម) ។

### ដំណាក់កាលលូតលាស់

VE – ដុះពន្លក

VC – កូទីឡេដុង

V1 – ខ្នែងទី ១

V2 – ខ្នែងទី ២

V3 - ខ្នែងទី ៣

V(n) - ខ្នែងទី អិន

### ដំណាក់កាលបន្តពូជ

R1 – កំណេរកំណើតកញ្ចុំផ្កា

R2 – កញ្ចុំផ្កាពេលលេញ

R3 – កំណេរកំណើតផ្លែ

R4 – ផ្លែពេញលេញ

R5 – ចាប់ផ្តើមដាក់គ្រាប់

R6 – ដាក់គ្រាប់ពេញលេញ

R7 – ចាប់ផ្តើមទុំ

R8 – ទុំពេញលេញ



